នៅចំពោះមុខអង្គបុរេជំនុំជម្រះ

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០៤/១/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៥០)

ភាគីដាក់ឯកសារ: ក្រុមការពារក្តីរបស់អ្នកស្រី អ៊ឹម ចែម

ដាក់ជូន: អង្គបុរេជំនុំជម្រះ

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១៧

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 12-June-2018, 09:13
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ សាធារណៈ/Public

ប្រភេទចំណាត់ថ្នាក់ឯកសារ

ពិនិត្យឡើងវិញចំពោះចំណាត់ថ្នាក់ឯកសារបណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**ចម្លើយតបរបស់ អ៊ឹម ចែម ទៅនឹងសំណើរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីជាតិ សុំពន្យារពេល និងសុំការអនុញ្ញាតដាក់ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយមានសំអាងហេតុ ជាភាសាអង់គ្លេសមុនសិន ដោយសំណៅជាភាសាខ្មែរនឹងដាក់តាមក្រោយ (D308/3/1/4)**

---

**ដាក់ដោយ÷**

**សហមេធាវី**

ប៊ិត ស៊ាងលឹម

Wayne JORDASH, QC

**ផ្ញើជូន÷**

**ចៅក្រមអង្គបុរេជំនុំជម្រះ÷**

ចៅក្រម ប្រាក់ គីមសាន

ចៅក្រម BAIK Kang Jin

ចៅក្រម ន៍យ ធុល

ចៅក្រម Oivier BEAUVALLET

ចៅក្រម ហួត វុទ្ធី

**សហព្រះរាជអាជ្ញា÷**

លោកស្រី ជា លាង

លោក Nicholas KOUMJIAN

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ទាំងអស់ក្នុងសំណុំរឿង០០៤/១**

## I. សេចក្តីផ្តើម

១. អ្នកស្រី អ៊ឹម ចែម តាមរយៈសហមេធាវីរបស់អ្នកស្រី ("ក្រុមការពារក្តី") តទៅនេះ សូមដាក់ជូននូវចម្លើយតបទៅនឹង*សំណើរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីជាតិសុំពន្យារពេល និងសុំការអនុញ្ញាតដាក់ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ជាភាសាអង់គ្លេសសិន ដោយសំណៅជាភាសាខ្មែរនឹងដាក់តាមក្រោយ* ("សំណើ")[1] ។

២. ក្រុមការពារក្តីសូមស្នើថា ទាំងសំណើ និងចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ(សំអាងហេតុ) ដែលមិនទាន់ត្រូវបានដាក់របស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីជាតិគួរតែត្រូវច្រានចោល ពីព្រោះមានកំហុសនីតិវិធីដោយសារតែកង្វះ*ការជាប់ពាក់ព័ន្ធទៅនឹងព្យសនកម្ម* ។ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលពាក្យសុំរបស់ពួកគាត់ត្រូវបានបដិសេធដោយសហចៅក្រមស៊ើបអង្កេតកាលពីថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៧[2] ក្នុងសំណុំរឿង004/1 ហើយខកខានមិនបានធ្វើការជំទាស់តវ៉ាចំពោះសេចក្តីសម្រេចនេះ គឺលែងត្រូវបានចាត់ទុកថាជាភាគីនៅក្នុងសំណុំរឿង004/1ទៀតហើយ ។ ចំណែកក្រុមអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលតំណាងដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីជាតិ ("អ្នកសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី") ក៏លែងមានសិទ្ធិក្នុងការបញ្ចេញយោបល់នៅក្នុងសំណុំរឿង004/1 ។

៣. ប្រសិនបើអង្គបុរេជំនុំជម្រះសម្រេចថាអាចទទួលយកបានចំពោះសំណើ និងចម្លើយតបនាពេលខាងមុខនៃអ្នកសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ទៅនឹងបណ្តឹងឧទ្ធរណ៍លើដីកាដំណោះស្រាយ

---

1 សំណើរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីជាតិ សុំពន្យារពេល និងសុំការអនុញ្ញាតដាក់ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ជាភាសាអង់គ្លេសសិន ដោយសំណៅជាភាសាខ្មែរនឹងដាក់តាមក្រោយ ធ្វើនៅថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៧, ឯកសារ **D308/3/1/4** ។

2 ដីកាសម្រេចលើភាពអាចទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ធ្វើនៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ២០១៧, ឯកសារ **D307** ("ដីកាបដិសេធ") ។

(សំអាងហេតុ) ក្រុមការពារក្តីមានសិទ្ធិក្នុងការដាក់ការឆ្លើយតប ព្រមទាំងស្នើសុំពេលវេលា និងចំនួនសន្លឹកបន្ថែមសម្រាប់គោលបំណងដូចគ្នានេះ ។

## II. សាវតា

៤. នៅថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩ សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី Petit បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ ដើម្បីបើកការស៊ើបអង្កេតប្រឆាំងអ្នកស្រី អ៊ឹម ចែម[3] ។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមមួយចំនួន ត្រូវបានដាក់ដាច់ដោយឡែកពីគ្នាជាបន្តបន្ទាប់ រួមមានដូចជាដីកាចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១១, ដីកាចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤, ដីកាចុះថ្ងៃទី៤ ខែតុលា ឆ្នាំ២០១៥ និងដីកាចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៥[4] ។

៥. នៅថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៥ សហចៅក្រមស៊ើបអង្កេតបានបិទកិច្ចស៊ើបសួរប្រឆាំងនឹងអ្នកស្រី អ៊ឹម ចែម[5] ។

៦. នៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៧ សហចៅក្រមស៊ើបអង្កេតបានដាក់ចេញផ្នែកសេចក្តីសម្រេចនៃដីកាដំណោះស្រាយនៅក្នុងសំណុំរឿង០០៤/១ ចំណែកសេចក្តីសំអាងហេតុពេញលេញនឹងត្រូវដាក់ចេញតាមក្រោយ[6] ។ នៅថ្ងៃដដែលនេះ សហចៅក្រមស៊ើបអង្កេតបានចេញដីកាកំណត់លើភាពអាចទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដោយសម្រេចបដិសេធនូវរាល់អ្នកសុំ

---

[3] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣របស់សហព្រះរាជអាជ្ញា ថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩, ឯកសារ **D1** ។

[4] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មនៅតំបន់១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម ធ្វើនៅថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១១, ឯកសារ **D65** ។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ ឬអំពើហិង្សាយេនឌ័រ ធ្វើនៅថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤, ឯកសារ **D191** ។ ចម្លើយតបទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមពាក់ព័ន្ធនឹងវត្តតាមាក់ ធ្វើនៅថ្ងៃទី ៤ ខែ សីហា ឆ្នាំ២០១៥, ឯកសារ **D254/1** ។ ចម្លើយតបទៅនឹងដីកាបញ្ជូនរឿងទៅពិនិត្យ ចុះថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០១៥ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ពាក់ព័ន្ធនឹងវិសាលភាពនៃកិច្ចស៊ើបសួរទៅក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំ នៅក្នុងដំបន់១ និងតំបន់៤ ធ្វើនៅថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១៥, ឯកសារ **D272/1** ។

[5] សេចក្តីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរប្រឆាំង អ៊ឹម ចែម ចុះនៅថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៥, ឯកសារ **D285** ។

[6] ដីកាដំណោះស្រាយ (ផ្នែកសេចក្តីសម្រេច) ចុះនៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៧, ឯកសារ **D308** ។

តាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ក្នុងសំណុំរឿង០០៤/១ ("ដីកាបដិសេធ")[7] ។

៧. នៅថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយនៃសំណុំរឿង០០៤/១ ដែលមានសំអាងហេតុពេញលេញ និងសម្រេចច្រានចោលបទចោទប្រកាន់ទាំងអស់ប្រឆាំងនឹងអ្នកស្រី អ៊ឹម ចែម[8] ។

៨. នៅថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១៧ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់សេចក្តីជូនដំណឹងនៃការដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ)[9] ហើយនៅថ្ងៃទី ៩ ខែ សីហា ឆ្នាំ ២០១៧ បណ្តឹងឧទ្ធរណ៍ត្រូវបានដាក់ទាំងពីរភាសា គឺភាសាខ្មែរ និងអង់គ្លេស[10] ។

៩. ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៧ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីជាតិ សំ សុគង់ បានដាក់សំណើស្នើសុំការពន្យារពេល និងសុំការអនុញ្ញាតដាក់ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ជាភាសាអង់គ្លេសសិន ដោយសំណៅជាភាសាខ្មែរនឹងដាក់តាមក្រោយ[11] ។ នៅថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៧ អង្គបុរេជំនុំជម្រះបានណែនាំដល់ភាគីនៃសំណុំរឿង០០៤/១ ឱ្យរៀបចំឆ្លើយតបទៅនឹងសំណើនេះ ត្រឹម

---

7 ដីកាសម្រេចលើភាពអាចទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ធ្វើនៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ២០១៧, ឯកសារ **D307** ។

8 ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧, ឯកសារ **D308/3** ("ដីកាដំណោះស្រាយ (សំអាងហេតុ)") ។

9 សៀវភៅចុះបណ្តឹងឧទ្ធរណ៍លើការជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិ អំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (សម្អាងហេតុ) ធ្វើនៅថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១៧, ឯកសារ **D308/3/1** ។

10 បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ធ្វើនៅថ្ងៃទី ៩ ខែ សីហា ឆ្នាំ ២០១៧, ឯកសារ **D308/3/1/1** ។

11 សំណើរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីជាតិ សុំពន្យារពេល និងសុំការអនុញ្ញាតដាក់ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ជាភាសាអង់គ្លេសសិន ដោយសំណៅជាភាសាខ្មែរនឹងដាក់តាមក្រោយ ធ្វើនៅថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៧, ឯកសារ **D308/3/1/4** ។

វេលាម៉ោង ១:០០ រសៀល នៃថ្ងៃច័ន្ទ ទី ២១ ខែ សីហា ឆ្នាំ ២០១៧[12] ។

## III. ច្បាប់ជាធរមាន

១០. វិធាន៧៥ នៃវិធានផ្ទៃក្នុង ចែង*ក្នុងចំណោមផ្នែកដទៃទៀត*ដូចតទៅ:

១. លើកលែងតែមានបទប្បញ្ញត្តិចែងផ្សេងនៅក្នុងវិធានផ្ទៃក្នុងនេះ គ្រប់ពាក្យបណ្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះត្រូវតែធ្វើឡើងក្នុងអំឡុងពេល១០(ដប់)ថ្ងៃ គិតចាប់ពីថ្ងៃដែលទទួលបានសេចក្តីជូនដំណឹងពីសេចក្តីសម្រេច ឬ ដីកា ។ មេធាវីរបស់ជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណីអាចដាក់បណ្តឹងឧទ្ធរណ៍ក្នុងនាមជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណីបាន ។

...

៣. ការដាក់សារណាបណ្តឹងឧទ្ធរណ៍ ត្រូវធ្វើឡើងដោយម្ចាស់បណ្តឹងឧទ្ធរណ៍ទៅក្រឡាបញ្ជីនៃអង្គបុរេជំនុំជម្រះក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានសេចក្តីជូនដំណឹងពីសេចក្តីសម្រេច ឬ ដីកា ។ ក្នុងកាលៈទេសៈពិសេស រយៈពេលកំណត់នេះអាចពន្យារបាន ។

១១. វិធាន៣៩(១) នៃវិធានផ្ទៃក្នុងចែងថា:

១. គ្រប់ពេលវេលាកំណត់ទាំងអស់ដែលមានចែងក្នុងច្បាប់ជាធរមាន វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងសេចក្តីសម្រេចរបស់ចៅក្រមតាមករណីសមស្របណាមួយត្រូវតែគោរព ។ ក្នុងករណីនេះ ការមិនបានគោរពតាមកាលកំណត់ គឺនាំឱ្យកិច្ចដែលបានធ្វើនោះត្រូវចាត់ទុកជាអស់សុពលភាព ។

១២. សេចក្តីណែនាំអនុវត្តមាត្រា ៩ ស្តីពីការដាក់ឯកសារចែងថា:

ឯកសារអាចដាក់ក្រោយរយៈពេលកំណត់ ដូចមានចែងនៅក្នុងវិធាន៣៩ នៃវិធាន

---

[12] សារអេឡិចត្រូនិកពីមន្ត្រីផ្នែកសំណុំរឿងទៅកាន់ភាគីនៃសំណុំរឿង០០៤/១ ដែលមានចំណងជើងថា "ការជូនដំណឹង: សំណុំរឿងលេខ: ០០៤/១/០៧-០៩-២០០៩-អវតក/កសចស (អបជ៥០) សេចក្តីណែនាំរបស់អង្គបុរេជំនុំជម្រះដល់ភាគី តាមរយៈអ៊ីម៉ែល" ធ្វើនៅថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៧ [ភ្ជាប់ក្នុងឧបសម្ព័ន្ធ ក] ។

ផ្ទៃក្នុង ។ នៅក្នុងករណីនេះ បុគ្គលដែលដាក់ឯកសារត្រូវបញ្ជាក់ពីមូលហេតុនៃការយឺតយ៉ាវក្នុងការដាក់ឯកសារនៅលើគំរូពាក្យសុំដាក់ឯកសារ ។ ចៅក្រម ឬអង្គជំនុំជម្រះដែលទទួលបានឯកសារនោះត្រូវសម្រេចថា ទទួល ឬមិនទទួលយកឯកសារនោះ ទោះបីជាឯកសារនោះដាក់យឺតយ៉ាវក៏ដោយ[13] ។

## IV. ចម្លើយតប

១៣. ក្រុមការពារក្តីសន្មតថាសំណើនេះ គឺជាសំណើមានកំហុសនីតិវិធី ។ សហចៅក្រមស៊ើបអង្កេតបានសម្រេចបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ នៅក្នុងសំណុំរឿង ០០៤/១ កាលពីថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៧ ។ គ្មានដើមបណ្តឹងរដ្ឋប្បវេណីណាម្នាក់បានធ្វើការប្តឹងឧទ្ធរណ៍ទៅនឹងដីកាបដិសេធនេះទេ ចំណែកសិទ្ធិរបស់ពួកគេក្នុងការលើកឡើងអំពីការជំទាស់តវ៉ាឥឡូវនេះត្រូវបានផុតកំណត់ហើយ ។ អាស្រ័យហេតុនេះ អ្នកសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងនោះគឺខ្វះ*ការជាប់ពាក់ព័ន្ធទៅនឹងព្យសនកម្ម* ក្នុងការបញ្ចេញយោបល់នៅក្នុងសំណុំរឿង០០៤/១ ។ លើសពីនេះទៀត ដូចបានចង្អុលបង្ហាញនៅផ្នែកខាងក្រោម អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងនេះមិនអាចត្រូវបានអនុញ្ញាតឡើយ ចំពោះការស្វះស្វែង *ដាក់ស្តែង*គឺនៅក្នុងការដាក់សេចក្តីជូនដំណឹងពីការដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ដោយមិនទាន់ពេលវេលា ព្រមទាំងល្មើសជាមួយនឹងវិធានផ្ទៃក្នុង ។ ប្រសិនមាន "ចម្លើយតប" ទៅនឹងបណ្តឹងឧទ្ធរណ៍លើដីកាដំណោះស្រាយ (សំអាងហេតុ) នាពេលអនាគត ចម្លើយតបនោះក៏គួរតែត្រូវបានចាត់ទុកថាមិនអាចទទួលយកបានដោយសារមានកំហុសនីតិវិធី ។

<u>អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីខ្វះនូវឋានៈក្នុងការបញ្ចេញយោបល់នៅក្នុងសំណុំរឿង០០៤/១</u>

១៤. នៅក្នុងដីកាបដិសេធ សហចៅក្រមស៊ើបអង្កេតបានច្រានចោលដោយឥតស្រពេចស្រពិលរាល់អ្នកសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នៅក្នុងសំណុំរឿង០០៤/១ ដោយផ្អែកលើមូលដ្ឋាន

---

[13] សេចក្តីណែនាំអនុវត្ត អ.វ.ត.ក/០១/២០០៧/វិ.លើកទី៨ ធ្វើនៅថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១២ ("សេចក្តីណែនាំការអនុវត្ត") មាត្រា ៩ ។

ដូចខាងក្រោម:

យើងបានលើកលែងការចោទប្រកាន់ទាំងអស់នៅក្នុងសំណុំរឿង០០៤/១ ពីព្រោះ ថា អ៊ឹម ចែម ជា ជនត្រូវចោទតែម្នាក់គត់នៅក្នុងសំណុំរឿងនេះ មិនស្ថិតនៅក្នុង យុត្តាធិការរបស់ អ.វ.ត.ក ឡើយ ។ ហេតុនេះ អ្នកដាក់ពាក្យសុំតាំងខ្លួនជា ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០៤/១ លែងមានសិទ្ធិប្តឹងគាត់ទៀត ហើយតាមច្បាប់របស់ អ.វ.ត.ក ។ អាស្រ័យហេតុនេះ ពាក្យសុំរបស់ពួកគាត់ ត្រូវបានបដិសេធ[14] ។

១៥. អនុលោមតាមវិធាន២៣ និងវិធាន៧៤ នៃវិធានផ្ទៃក្នុង សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ទាំងឡាយមានសិទ្ធិនឹងធ្វើការប្តឹងឧទ្ធរណ៍ចំពោះដីកាបដិសេធ[15] ។ ដូចដែលបានគាំទ្រដោយ តុលាការព្រហ្មទណ្ឌអន្តរជាតិ ជនរងគ្រោះដែលចូលរួមនៅក្នុងដំណើរការនីតិវិធីត្រូវតែធ្វើការ ដោះស្រាយបញ្ហានៃភាពអាចទទួលយកបានចំពោះពាក្យសុំរបស់ខ្លួនមុនពេលពួកគេអាចមានសិទ្ធិ ចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីសំខាន់ៗទៅបាន[16] ។ ការដែលអ្នកសុំតាំងខ្លួនជាដើមជាដើម

---

[14] ដីកាបដិសេធ, ឯកសារ **D307** ត្រង់កថាខណ្ឌ ១១ ។

[15] វិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (វិសោធនកម្មលើកទី៩) អនុម័តនៅថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០៧ (វិសោធនកម្មនៅថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៥) ("វិធានផ្ទៃក្នុង"), វិធាន២៣*ស្ទួន*(៣) ចែងថា ["នៅពេលចេញ ដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតត្រូវសម្រេចអំពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹង រដ្ឋប្បវេណីដែលនៅសេសសល់ទាំងអស់ ដោយដីកាដោយឡែក ។ ដីកានេះ ត្រូវបើកផ្លូវប្តឹងឧទ្ធរណ៍សង្ខេបដោយភាគី ឬ អ្នកសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដូចដែលមានចែងនៅក្នុងវិធាន ៧៧ *ស្ទួន* ។..."] ។ វិធាន៧៤(៤)(ក) ចែងថា ["ដើមបណ្តឹងរដ្ឋប្បវេណីអាចធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតដូចខាងខាងក្រោម: ក- ការបដិសេធពាក្យសុំឱ្យមានកិច្ចស៊ើបសួរណាមួយ ដែលអនុញ្ញាតក្រោមវិធានផ្ទៃក្នុង ។"] ។

[16] ស្ថានភាពនៅសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ [*Congo*] លេខ (ICC-01/04-418), អង្គបុរេជំនុំជម្រះ I, ដីកាសម្រេច លើសំណើរបស់ OPCV ធ្វើនៅថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០០៧, ត្រង់កថាខណ្ឌ ១៦ ["មានចៅក្រមតែម្នាក់គត់ដែលសង្កេត ឃើញថា ការមិនជូនដំណឹងពីសេចក្តីសង្កេតនានាក្នុងវិធាន ៨៩(១) គឺមិនធ្វើអោយប៉ះពាល់ដល់អ្នកដាក់ពាក្យសុំនោះទេ ។ អនុលោមតាមវិធាន៨៩(២) អ្នកដាក់ពាក្យសុំមានសិទ្ធិដាក់ពាក្យសុំថ្មីប្រសិនបើពាក្យសុំរបស់ពួកគេត្រូវបានបដិសេធ ។ ទោះបីជាយ៉ាងណាក្តី ពួកគេមិនមានសិទ្ធិឆ្លើយតបទៅនឹងសេចក្តីសង្កេតនានា ដែលធ្វើឡើងដោយអយ្យការ និងក្រុមការ ពារក្តី និងក៏មិនអាចធ្វើការស្នើសុំការអនុញ្ញាតដើម្បីធ្វើការប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះទៅលើ អង្គសេចក្តីនៃពាក្យសុំរបស់ពួកគេឡើយ ។" ] ។ *សូមមើល*, ស្ថានភាពនៅសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ [*Congo*]

បណ្ដឹងរដ្ឋប្បវេណីមិនបានជំទាស់ជាមួយនឹងដីកាបដិសេធដោយជោគជ័យទេនោះ បានសេចក្ដីថា អស់រយៈ១៧៧ថ្ងៃ ក្រោយពីការចេញសេចក្ដីជូនដំណឹងអំពីដីកាបដិសេធដែលមិនអាចតវ៉ាបាន វាស្មើនឹងការយល់ព្រមទទួលយកនូវកង្វះខាតនៃ*ការជាប់ពាក់ព័ន្ធទៅនឹងព្យសនកម្ម* សម្រាប់ដាក់សំណើ និងបញ្ចេញយោបល់ចំពោះដីកាដំណោះស្រាយ (សំអាងហេតុ) ។

១៦. លើសពីនេះ បើទោះបីជាអ្នកសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីមានឋានៈក្ដី ក៏គ្រោះដែលពួកគេបានលើកឡើងថាបានទទួលរង គឺមិនជាប់ទាក់ទងទៅនឹងបទចោទប្រកាន់ប្រឆាំងអ្នកស្រី អ៊ឹម ចែម ដែរ[17] ។ រាល់ហេតុផលទាំងអស់ដូចបានរៀបរាប់ខាងលើ ក្រុមការពារក្ដីសូមស្នើថាសំណើនេះ ជា

---

លេខ (ICC-01/04-164-tENG), អង្គបុរេជំនុំជម្រះ I, សេចក្ដីសម្រេចលើពាក្យសុំរបស់អ្នកដាក់ពាក្យសុំ [លេខ] a/0001/06 ទៅ a/0003/06 សុំការអនុញ្ញាតសម្រាប់ធ្វើការឆ្លើយតបទៅនឹងសេចក្ដីសង្កេតនានា របស់ព្រះរាជអាជ្ញា និងមេធាវីការពារក្ដីអន្តរជាតិពិសេស ចុះថ្ងៃទី ៧ ខែ កក្កដា ឆ្នាំ ២០០៦ ។ សំណុំរឿងរបស់ *The Prosecutor ទល់នឹង Thomas Lubanga Dyilo*, លេខ (ICC-01/04-01/06-936), អង្គជំនុំជម្រះ I, សំណើសុំការដាក់សារណាស្ដីពីប្រធានបទនានាដែលតម្រូវឱ្យមានការកំណត់សម្រេចឆាប់ៗ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៧, ត្រង់កថាខណ្ឌ ៥ ។

[17] លោក សំ សុគង់ ជាសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីជាតិតំណាងឱ្យអ្នកសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីចំនួន ៥៨នាក់ ។ តាមរយៈការពិនិត្យមើលនូវរាល់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់បានឱ្យដឹងថា គ្មានពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីណាមួយពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដែលរងការចោទប្រកាន់ថាបានប្រព្រឹត្តនៅមន្ទីរសន្តិសុខភ្នំទ្រយោង ឬនៅការដ្ឋានស្ពានស្រែងឡើយ ។ *សូមមើល*, ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ Rob Hamill ធ្វើនៅថ្ងៃទី ៧ ខែ មីនា ឆ្នាំ ២០១១ ឯកសារ **D5/2** ។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ចឹង ភី ធ្វើនៅថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០០៩ ឯកសារ **D5/40** ។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ជា សាវី ធ្វើនៅថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០០៩ ឯកសារ **D5/43** ។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ហេ ផែន ធ្វើនៅថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០០៩ ឯកសារ **D5/44** ។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ខាន់ ប៊ុនឿន ធ្វើនៅថ្ងៃទី ៣ ខែ កញ្ញា ឆ្នាំ ២០០៩ ឯកសារ **D5/48** ។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ សោ ឡាង ធ្វើនៅថ្ងៃទី ៣ ខែ កក្កដា ឆ្នាំ ២០០៩ ឯកសារ **D5/53** ។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ នួន យឹន ធ្វើនៅថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ២០០៩ ឯកសារ **D5/54** ។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ស៊ុម ឃន ធ្វើនៅថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០០៩ ឯកសារ **D5/56** ។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ជា ហេង ធ្វើនៅថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០០៩ ឯកសារ **D5/57** ។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ខៀវ ប៊ុនធឿន ធ្វើនៅថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០០៩ ឯកសារ **D5/58** ។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ចិច សុធា ធ្វើនៅថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០០៩ ឯកសារ **D5/66** ។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ សង់ សយ ធ្វើនៅថ្ងៃទី ៩ ខែ សីហា ឆ្នាំ ២០០៩ ឯកសារ **D5/67** ។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ឈុំ វណ្ណី ធ្វើនៅថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៩ ឯកសារ **D5/68** ។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ពែង សាន្ត ធ្វើនៅថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩

ឯកសារ **D5/71** ។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ កី សើង ធ្វើនៅថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០០៩ ឯកសារ **D5/72** ។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ផាន់ សារ៉ង ធ្វើនៅថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ២០០៩ ឯកសារ **D5/73** ។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ គឹម ផេង ធ្វើនៅថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០០៩ ឯកសារ **D5/75** ។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ចៀវ ហេង ធ្វើនៅថ្ងៃទី ៧ ខែ តុលា ឆ្នាំ ២០០៩ ឯកសារ **D5/80** ។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ញ៉ឹល អ៊ី ធ្វើនៅថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០០៩ ឯកសារ **D5/90** ។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ សី សាង ធ្វើនៅថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០៩ ឯកសារ **D5/92** ។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ស្អួន ឡូរ ធ្វើនៅថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០០៩ ឯកសារ **D5/93** ។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ កែវ ហ្វៅ ធ្វើនៅថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០៩ ឯកសារ **D5/96** ។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ឃៀម ប៊ូ ធ្វើនៅថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០៩ ឯកសារ **D5/98** ។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ កៅ ផារី ធ្វើនៅថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០០៩ ឯកសារ **D5/99** ។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ សើន ដើង ធ្វើនៅថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ២០០៩ ឯកសារ **D5/109** ។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ វ៉ើន វ៉ន ធ្វើនៅថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០៩ ឯកសារ **D5/111** ។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ទិត សុផារី ធ្វើនៅថ្ងៃទី ៩ ខែ កក្កដា ឆ្នាំ ២០០៩ ឯកសារ **D5/113** ។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ឡៃ ហឿន ធ្វើនៅថ្ងៃទី ៩ ខែ កក្កដា ឆ្នាំ ២០០៩ ឯកសារ **D5/116** ។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ដួង សៀន ធ្វើនៅថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ឯកសារ **D5/135** ។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ គឹម ហួយ ធ្វើនៅថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០០៨ ឯកសារ **D5/143** ។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ប៊ួយ ហួយ ធ្វើនៅថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០០៨ ឯកសារ **D5/156** ។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ហាង ងួន ធ្វើនៅថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០០៨ ឯកសារ **D5/158** ។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ Timothy Scott DEEDS ធ្វើនៅថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១១ ឯកសារ **D5/313** ។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ណន យ៉េម ធ្វើនៅថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០៩ ឯកសារ **D5/991** ។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ង៉ូវ ញ៉ ធ្វើនៅថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០៩ ឯកសារ **D5/992** ។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ នាង សាខន ធ្វើនៅថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០០៩ ឯកសារ **D5/1031** ។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ព្រុំ សាម៉ុន ធ្វើនៅថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០០៩ ឯកសារ **D5/1047** ។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ស៊ុំ យ៉ឹម ធ្វើនៅថ្ងៃទី ៣ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ឯកសារ **D5/1096** ។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ជា ចន្ទី ធ្វើនៅថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ឯកសារ **D5/1097** ។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ហើយ សាន្ត ធ្វើនៅថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០០៩ ឯកសារ **D5/1098** ។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ឆាយ សុខ ធ្វើនៅថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៨ ឯកសារ **D5/1115** ។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ សេវ រៀម ធ្វើនៅថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ **D5/1116** ។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ប៉ែន ឌី ធ្វើនៅថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ **D5/1117** ។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ថាវ និន ធ្វើនៅថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ **D5/1146** ។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ សៅ និមិត្ត ធ្វើនៅថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០០៩ ឯកសារ **D5/1233** ។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ សៀង ចាន់ធី ធ្វើនៅថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០០៧ ឯកសារ **D5/1234** ។ ពាក្យសុំតាំងខ្លួនជា

សំណើដែលមិនអាចទទួលយកបាន ដោយសារកង្វះខាតនូវ *ការជាប់ពាក់ព័ន្ធទៅនឹងព្យសនកម្ម* ។

<u>អ្នកសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី *ជាក់ស្តែង*គឺបានរំលោភបំពាននូវវិធានផ្ទៃក្នុងនៅក្នុងការជូនដំណឹងអំពីការដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ)</u>

១៧. ក្រៅពីភាសានៃសំណើទាក់ទងនឹងការសុំពន្យារពេលក្នុង “ការឆ្លើយតប” ទៅនឹងបណ្តឹងឧទ្ធរណ៍លើដីកាដំណោះស្រាយ (សំអាងហេតុ) ក្រុមការពារក្តីយល់ឃើញថា អ្នកសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី តាមពិតទៅមានបំណង *ជាក់ស្តែង*ដាក់នូវសេចក្តីជូនដំណឹងពីការដាក់បណ្តឹងឧទ្ធរណ៍តាមរយៈសំណើ ។ ការប៉ុនប៉ងនេះ គឺជាការបញ្ចៀសយ៉ាងមានប្រសិទ្ធិភាពនូវយន្តការនីតិវិធីពេញច្បាប់ ដែលបានបើកចំហសម្រាប់ភាគីទាំងអស់ធ្វើការតតាំងជាមួយនឹងការរកឃើញនានានៃដីកាដំណោះស្រាយ ។

១៨. ភាសានៅក្នុងវិធានផ្ទៃក្នុងគឺស្រួលយល់ ។ អនុលោមតាមវិធាន៧៤(៤)(ឞ) នៃវិធានផ្ទៃក្នុង *ដើមបណ្តឹងរដ្ឋប្បវេណី* ពោលគឺពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានទទួលយកដោយដីការបស់សហចៅក្រមស៊ើបអង្កេត អាចធ្វើការប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាលើកលែងការចោទប្រកាន់បាន ក្នុងករណីដែលសហព្រះរាជអាជ្ញាធ្វើបណ្តឹងឧទ្ធរណ៍ដែរ ។ ទោះជាយ៉ាងណាក្តី

---

ដើមបណ្តឹងរដ្ឋប្បវេណីរបស់ សោម អឿន ធ្វើនៅថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០០៩ ឯកសារ **D5/1235** ។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ពេជ្រ សុធា ធ្វើនៅថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩ ឯកសារ **D5/1236** ។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សុខ សឿន ធ្វើនៅថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០០៩ ឯកសារ **D5/1237** ។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ប៉ាត សោម ធ្វើនៅថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៩ ឯកសារ **D5/1238** ។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ង៉ូក យ៉ាន ធ្វើនៅថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០៧ ឯកសារ **D5/1239** ។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ម៉ាន យូសុះ ធ្វើនៅថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៨ ឯកសារ **D5/1240** ។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ អេល ម៉ើ ធ្វើនៅថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០០៨ ឯកសារ **D5/1241** ។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ម៉ៅ ហា ធ្វើនៅថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ២០០៨ ឯកសារ **D5/1242** ។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ អ៊ុន នី ធ្វើនៅថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៩ ឯកសារ **D5/1395** ។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ងួន ឈុនហៃ ធ្វើនៅថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៩ ឯកសារ **D5/1404** ។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ម៉ៅ សើឡេស ធ្វើនៅថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ ២០០៩ ឯកសារ **D5/1405** ។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ចៅ ឡាង ធ្វើនៅថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០០៩ ឯកសារ **D5/1406** ។

វិធានផ្ទៃក្នុងមិនបានចែងថា រាល់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងឡាយណា ដែលមិនត្រូវបានទទួលយកដោយសហចៅក្រមស៊ើបអង្កេត អាចធ្វើការឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍មួយ ដែលប្តឹងដោយសហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាលើកលែងការចោទប្រកាន់នោះទេ កុំថាឡើយអាចធ្វើការប្តឹងឧទ្ធរណ៍លើដីកាលើកលែងការចោទប្រកាន់ ប្រសិនបើពួកគេបានខកខានមិនជំទាស់តវ៉ានឹងដីកាដែលរកឃើញថា ខ្លួនមិនអាចត្រូវបានទទួលយក ។

១៩. អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីឥឡូវនេះ កំពុងតែស្វះស្វែងបញ្ចៀសនូវវិធីតឹងរ៉ឹងទាំងនេះតាមរយៈសំណើ ដោយអះអាងថាពួកគេធ្វើការ "ឆ្លើយតប" ទៅនឹងបណ្តឹងឧទ្ធរណ៍លើដីកាដំណោះស្រាយ (សំអាងហេតុ) ។ សេចក្តីជូនដំណឹងស្តីពីបណ្តឹងឧទ្ធរណ៍នេះ *ជាក់ស្តែង* គឺផុតសុពលភាពហើយ ។ តុលាការបានច្រានចោលការដាក់ឯកសារយឺតយ៉ាវនៅក្នុងសំណុំរឿងមួយចំនួន ដែលជាលទ្ធផលកើតចេញពីកង្វះខាតនូវការយកចិត្តទុកដាក់លើបញ្ហាអវត្តមាននៃមូលហេតុដ៏ល្អណាមួយ[18] ។ អវត្តមាននូវការពន្យល់បន្ថែម មានន័យថាវាជាការបរាជ័យរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីជាតិក្នុងការមិនអនុវត្តសិទ្ធិជំទាស់តវ៉ាលើភាពអាចទទួលយកបាននៃពាក្យសុំ

---

[18] *សំណុំរឿង មាស មុត* ០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ.០៦), សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ ទាក់ទិននឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិជំទាស់នឹង "សេចក្តីសម្រេចលើការដាក់ឡើងវិញនូវសំណើសុំបំពេញកិច្ចស៊ើបសួរទាំងបី", មតិយោបល់របស់ចៅក្រម ប្រាក់ គឹមសាន ចៅក្រម ន័យ ថុល និងចៅក្រម ហួត វុទ្ធី ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១១, ឯកសារ **D26/1/3** ត្រង់កថាខណ្ឌ១-៣ ["ត្រង់ចំណុចដែលចៅក្រម ប្រាក់ គឹមសាន ចៅក្រម ន័យ ថុល និងចៅក្រម ហួត វុទ្ធី បានទទួលសំឡេងគាំទ្រក្នុងការមិនអនុញ្ញាតមិនទទួលស្គាល់នូវបណ្តឹងឧទ្ធរណ៍ (លើសេចក្តីសម្រេចដែលយល់ស្របឱ្យសំណើសុំបំពេញកិច្ចស៊ើបសួរដែលអស់ពេលកំណត់) ដោយសារអង្គហេតុដែលថាមានផ្នែកខ្លះ បើតាមការយល់ឃើញរបស់ពួកគាត់ គឺថា សហព្រះរាជាអាជ្ញាអន្តរជាតិខ្លួនឯង "មិនបានប្រើប្រាស់សិទ្ធិ" ដែលមានក្នុងវិធានផ្ទៃក្នុង"] ។ សំណុំរឿង *The Prosecutor ទល់នឹង Clément Kayishema* និង *Obed Ruzindana*, សំណុំរឿងលេខ (ICTR-95-1-A), សាលដីកា (សំអាងហេតុ) ធ្វើនៅថ្ងៃទី ១ ខែមិថុនា ឆ្នាំ ២០០១ ត្រង់កថាខណ្ឌ ៤៤-៤៥។ *សូមមើលផងដែរ, សំណុំរឿង មាស មុត* ០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ.០៦), សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ ទាក់ទិននឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិជំទាស់នឹង "សេចក្តីសម្រេចលើការដាក់ឡើងវិញនូវសំណើសុំបំពេញកិច្ចស៊ើបសួរទាំងបី", មតិយោបល់របស់ចៅក្រម LAHUIS និងចៅក្រម DOWNING ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១១, ឯកសារ **D26/1/3** ត្រង់កថាខណ្ឌ១១-១៣ ["ត្រង់ចំណុចដែលចៅក្រម LAHUIS និងចៅក្រម DOWNING បានទទួលសំឡេងគាំទ្រក្នុងការអនុញ្ញាតទទួលយកនូវបណ្តឹងឧទ្ធរណ៍ ដោយសារសហព្រះរាជអាជ្ញាអន្តរជាតិបានបង្ហាញនូវការយកចិត្តទុកដាក់ចំពោះការងារ"] ។

មួយចំនួនរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលអាចកើតចេញមកពីកង្វះខាតនៃភាពយកចិត្តទុកដាក់ក្នុងការអនុវត្តការងាររបស់ខ្លួន ។ ទោះក្នុងករណីណាក៏ដោយ គ្មានទេមូលហេតុដ៏ល្អ ឬការអះអាងសមហេតុផលណាមួយត្រូវបានលើកឡើងនៅក្នុងសំណើ ។ សំណើនេះមិនបានផ្តល់នូវមូលដ្ឋានអ្វី ដើម្បីអាចធ្វើការបកស្រាយឱ្យបានទូលំទូលាយនូវក្របខ័ណ្ឌច្បាប់របស់ អ.វ.ត.ក ក្នុងការទទួលយក "ចម្លើយតប" ទៅនឹងបណ្តឹងឧទ្ធរណ៍នៃដីកាដំណោះស្រាយ (សំអាងហេតុ) ដែលជាការរំលោភបំពានលើវិធានផ្ទៃក្នុងឡើយ[19] ។

២០. ការអនុញ្ញាតអោយដើមបណ្តឹងរដ្ឋប្បវេណីដាក់សារណាមួយ ដែលធ្វើឡើងមិនទាន់ពេលវេលា និងដោយរំលោភបំពានទៅលើវិធានផ្ទៃក្នុង ជាការរារាំងនូវភាពឆាប់រហ័ស និងភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០៤/១ ក៏ដូចជារារាំងកិច្ចដំណើរការនីតិវិធីទូទៅនៅ អ.វ.ត.ក ។ *ជាចុងក្រោយ* ក្នុងការទទួលយកសំណើ និងតម្រុយស្តីពីការដាក់ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ជាការប្រឈមនឹងផលប៉ះពាល់ដល់ការអនុវត្តនូវកិច្ចដំណើរការនីតិវិធីប្រកបដោយយុត្តិធម៌ ហើយសម្រាប់ហេតុផលដូចដែលបានលើកឡើងទាំងអម្បាលម៉ាន នឹងធ្វើឱ្យអន្តរាយដល់ផលប្រយោជន៍យុត្តិធម៌នៅក្នុងសំណុំរឿងអ្នកស្រី អ៊ឹម ចែម ។

## V. សន្និដ្ឋាន

ចំពោះហេតុផលដែលបានលើកឡើងខាងលើ ក្រុមការពារក្តីសូមស្នើទៅអង្គបុរេជំនុំជម្រះមេត្តាសម្រេចបដិសេធមិនទទួលយកទាំងសំណើ និងចម្លើយតបនាពេលខាងមុខរបស់អ្នកសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទៅនឹងបណ្តឹងឧទ្ធរណ៍នៃដីកាដំណោះស្រាយ (សំអាងហេតុ) ។

សូមមេត្តាទទួលយកសារណានេះដោយគោរព ៕

---

[19] *សូមមើលជាទូទៅ, សំណុំរឿង នួន ជា និងអ្នកផ្សេងទៀត, សំណុំរឿង លេខ ០០២/១៩-០៩-២០០៧/អវតក/កសចស (អ.ប.ជ. ១០៤)*, សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១១, ឯកសារ **D427/4/15** ត្រង់កថាខណ្ឌ ២០-២១ ["ត្រង់ចំណុចដែលអង្គបុរេជំនុំជម្រះបានប្រកែកមិនធ្វើការបកស្រាយឱ្យបានទូលំទូលាយអំពីសិទ្ធិរបស់ម្ចាស់ពាក្យបណ្តឹងឧទ្ធរណ៍ ផ្នែកខ្លះនៃការយល់ឃើញដូច្នេះ គឺដោយសារថាសហមេធាវីនៃម្ចាស់បណ្តឹងឧទ្ធរណ៍មិនបានបង្ហាញពីការយកចិត្តទុកដាក់ក្នុងការអនុវត្តការងាររបស់ខ្លួន"] ។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជាថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១៧

សហមេធាវីការពារក្ដីអ្នកស្រី អ៊ឹម ចែម

| | |
|---|---|
| [ហត្ថលេខា] | [ហត្ថលេខា] |
| ប៊ិត ស៊ាងលឹម | Wayne JORDASH, QC |